# ផលប៉ះពាល់នៃកន្លែងថែទាំទៅលើការស្ដារនីតិសម្បទាកុមារ

Better Care Network

## សេចក្ដីសង្ខេបអំពីវីដេអូ

នៅក្នុងបរិបទជាច្រើន អភិក្រមរួមសម្រាប់កិច្ចគាំទ្រកុមាររងគ្រោះនៃអំពើជួញដូរ ឬ អំពើកេងប្រវ័ញ្ចផ្លូវភេទ គឺជាការផ្ដល់នូវសេវាស្ដារនីតិ សម្បទានៅតាមមណ្ឌលស្នាក់នៅ។ សេវាបែបនេះមានបំណងផ្ដល់ជូនទៅតាមអ្វីដែលជាសេចក្ដីត្រូវការរបស់កុមារ ទាក់ទងនឹងកិច្ចគាំទ្រផ្នែកសុវត្ថិភាព និងចិត្តសង្គម តាមរយៈការរៀបចំជាកម្រងសេវានៅក្នុងមណ្ឌលថែទាំកុមារ។ កំណើននៃការយល់ដឹងអំពីផលប៉ះពាល់អវិជ្ជមាននៃការថែទាំក្នុងមណ្ឌលទៅលើការអភិវឌ្ឍរបស់កុមារ និងសារៈសំខាន់នៃគ្រួសារ បាននាំឱ្យអ្នកអនុវត្តការងារផ្ទាល់ចោទសួរអំពីប្រសិទ្ធភាពនៃការស្ដារនីតិសម្បទានៅតាមមណ្ឌលស្នាក់នៅ។

នៅក្នុងវីដេអូនេះ អ្នកនឹងស្ដាប់លឺ ស្រីណា និង ចិន្ដា ដែលជាអ្នកអនុវត្តការងារផ្ទាល់មកពីអង្គការហារការ ប្រចាំប្រទេសកម្ពុជា ពិភាក្សាអំពីការរៀនសូត្ររបស់ពួកគេទាក់ទងនឹងផលប៉ះពាល់នៃកន្លែងថែទាំទៅលើការស្ដារនីតិសម្បទាកុមារ។ តាមរយៈការប្រៀបធៀបអំពីភាពខុសគ្នាដែលបានសង្កេតឃើញនៅក្នុងដំណើរការស្ដារនីតិសម្បទាសម្រាប់កុមារ ដែលបានទទួលកិច្ចគាំទ្រនៅក្នុងការថែទាំតាមគ្រួសាររបស់អង្គការហារការ ធៀបនឹងមណ្ឌលស្នាក់នៅរបស់ពួកគេ ស្រីណា និង ចិន្ដា បានគូសបញ្ជាក់អំពីមូលហេតុដែលអង្គការហារការ សម្រេចចិត្តបិទមណ្ឌលស្នាក់នៅរបស់ពួកគេ និងពង្រីកកម្មវិធីថែទាំតាមគ្រួសារ និងកម្មវិធីស្ដារនីតិសម្បទា តាមសហគមន៍របស់ពួកគេវិញ។ ស្រីណា និងចិន្ដា បានបន្តពិភាក្សាអំពីភាពខុសគ្នារវាងការធ្វើការទៅលើមនុស្សតែម្នាក់ ធៀបនឹងការធ្វើការជាប្រព័ន្ធសហគមន៍ និងគ្រួសារ ទាំងមូលសម្រាប់ការស្ដារនីតិសម្បទាកុមារ និងកិច្ចការពារកុមារ ជាពិសេសគឺពាក់ព័ន្ធនឹងនិរន្តរភាពនៃផលប៉ះពាល់។

## ចំណុចពិភាក្សា៖

### ផលវិបាកដែលកើតឡើងដោយអចេតនា

នៅក្នុងវីដេអូនេះ ស្រីណា និយាយអំពីវិបត្តិតានតឹងដែលបង្កឡើងដោយការដកកុមារណាម្នាក់ពីគ្រួសាររបស់ ពួកគេដើម្បីទទួលបានសេវាស្ដារនីតិសម្បទានៅតាមមណ្ឌល។ គាត់បានកត់សម្គាល់ថាវិបត្តិតានតឹងនៃការបំបែកកុមារពីគ្រួសារនៅទីបំផុតនាំឱ្យ អារម្មណ៍បាក់ស្មារតីកាន់តែធ្ងន់ធ្ងរឡើង និង រាំងស្ទះដល់ដំណើរការស្ដារនីតិសម្បទា អោយបានធូរស្រាលឡើងវិញ ដែលធ្វើឱ្យបាត់បង់ផលិតភាពរបស់សេវា ដែលសំដៅរួមចំណែកសម្រេចឱ្យបាននូវគោលដៅរួមនៃការស្ដារនីតិសម្បទា។ តាមរយៈការគូសបញ្ជាក់អំពីចំណុចនេះ ស្រីណាកំពុងទាញការយកចិត្តទុកដាក់ចំពោះផលវិបាកដោយអចេតនា ដែលអាចកើតឡើងនៅពេលដែលកម្មវិធីត្រូវបានរចនាឡើងដើម្បីឱ្យស្របទៅនឹងសេចក្ដីត្រូវការណាមួយជាក់លាក់ដោយពុំបានផ្ដល់ការពិចារណាសមស្របចំពោះសេចក្ដីត្រូវការជារួមរបស់កុមារ ការអភិវឌ្ឍ សិទ្ធិ និងទស្សនៈរបស់កុមារ។ ស្រីណា ចង្អុលបញ្ជាក់អំពីផលប៉ះពាល់ដែលចំណុចនេះបង្កឱ្យមានទៅលើសុខុមាលភាពផ្នែកសតិអារម្មណ និងចិត្តសាស្ត្ររបស់កុមារ ព្រមទាំងបង្កឱ្យមានសំនួរផ្ទុះបញ្ចាំងមួយដ៏សំខាន់ចំពោះអ្នកអនុវត្តការងារ “តើវាធ្វើឱ្យកុមារមានអារម្មណ៍ដូចម្ដេច?”

### នៅក្នុងបរិបទរបស់អ្នក៖

? តើអង្គការរបស់អ្នក ឬ សេវារបស់អ្នក បានខិតខំជម្រុញឱ្យមានការចូលរួមពីកុមារ និងអ្នកពាក់ព័ន្ធដទៃទៀតក្នុងការរចនាកម្មវិធីដោយ របៀបណា ដើម្បីធានាថាទស្សនៈ និង ចក្ខុវិស័យរបស់ពួកគេត្រូវបានយកមកពិចារណា? តើធ្វើដូចម្ដេចទើបអ្នកអាចធានាបានថាកុមារត្រូវបានផ្ដល់ឱកាសចូលរួមបន្ថែមទៀត ដើម្បីធានាថាការ វាយតម្លៃទៅលើភាពសក្ដិសិទ្ធរបស់កម្មវិធី ពិចារណាទៅលើទស្សនៈ និងបំណងប្រាថ្នារបស់កុមារ?

? តើសេវា ឬ កម្មវិធីរបស់អ្នក មានបំណងបំពេញសេចក្ដីត្រូវការ ឬ សិទ្ធិជាក់លាក់អ្វីខ្លះ? តើអភិក្រមរបស់អ្នកបង្កឱ្យមានផលប៉ះពាល់ទៅលើសេចក្ដីត្រូវការ និងសិទ្ធិដទៃទៀតយ៉ាងដូចម្ដេច និង តើមាន ផលវិបាកដោយចៃដន្យ ជាវិជ្ជមាន ឬ អវិជ្ជមានដែរឬទេ? សូមពិភាក្សាថាតើមានអភិក្រមដទៃទៀត ដែលអាច (ក) បង្ការការថយចុះមកវិញនូវសិទ្ធិ ឬ (ខ) បង្កើនផលប៉ះពាល់វិជ្ជមាននៃសេវារបស់អ្នក ទៅលើសិទ្ធិកុមារ និងសេចក្ដីត្រូវការជារួម ដែរឬទេ?

ចំណុចពិភាក្សា៖

## ចំណុចខ្លាំងនៃអភិក្រមប្រព័ន្ធសហគមន៍ និងគ្រួសារ

នៅក្នុងវីដេអូនេះ ស្រីណា និងចិន្តា ពិភាក្សាអំពីប្រយោជន៍នៃការផ្តល់កិច្ចគាំទ្រជូនដល់គ្រួសារទាំងមូល និង ការចូលរួមក្នុងការលើកកម្ពស់ការយល់ដឹងនៅក្នុងសហគមន៍ទាំងមូល ជាជាងការដែលគ្រាន់តែផ្តល់សេវា ស្តារនីតិសម្បទាជូនកុមារ។ គេបានលើកឡើងនូវអំណះ អំណាងថា អភិក្រមសហគមន៍នាំឱ្យទទួលបានផលប៉ះពាល់ប្រកបដោយនិរន្តរភាពសម្រាប់កុមារដែលកំពុងទទួលការស្តារនីតិសម្បទា និង ជួយបង្ការអំពើហិង្សាកុំឱ្យកើតឡើងបន្ថែមទៀតទៅលើកុមារ។ នេះដោយព្រោះតែអាស្រ័យដោយ អភិក្រមបែបនេះជួយពង្រឹងដល់ បណ្តាញគាំទ្រសង្គមរយៈពេលវែងសម្រាប់កុមារ ព្រមទាំងដោះស្រាយបាននូវបុព្វហេតុឫសគល់ដែលបង្កឱ្យមានភាពងាយ រងគ្រោះ និងហានិភ័យក្នុងគ្រួសារ និង សហគមន៍ទាំងមូល។

## នៅក្នុងបរិបទរបស់អ្នក៖

? តើកម្មវិធីរបស់អ្នកប្រើប្រាស់អភិក្រមប្រព័ន្ធសហគមន៍ និងគ្រួសារ ដោយធ្វើការងារជាមួយគ្រួសារ សហគមន៍ ឬ នៅកម្រិតសង្គម ដោយរបៀបណា ដើម្បីជាប្រយោជន៍សម្រាប់កុមារ?
តើមានវិធីដែលចំណុចនេះអាចត្រូវបាន លើកកម្ពស់ដែរឬទេ និង តើអ្នករំពឹងថានឹងមានប្រយោជន៍អ្វីបន្ថែមទៀតសម្រាប់កុមារ?

? ឆ្លុះបញ្ចាំងអំពីមូលហេតុឫសគល់ ដែលនាំឱ្យមានហានិភ័យចំពោះកុមារ និង បង្កើតឱ្យមានភាពងាយរងគ្រោះ ដោយផ្តោតលើកុមារជាក់លាក់ដែលអង្គការរបស់អ្នកគាំទ្រ។ តើកម្មវិធីរបស់អ្នកកំណត់គោលដៅមូលហេតុឫសគល់នៃហានិភ័យ អំពើហិង្សា ឬ ភាពងាយរងគ្រោះក្នុងកម្រិតណា និង តើអាចធ្វើអ្វីបានខ្លះ ដើម្បីជម្រុញសកម្មភាពនេះបន្ថែមទៀត?
តើត្រូវផ្លាស់ប្តូរអ្វីខ្លះ ដើម្បីបង្កើនកម្រិតដែល សេវារបស់អ្នក សំដៅទៅលើឫសគល់នៃបញ្ហាដែលត្រូវបានកំណត់ នៅកម្រិតផ្សេងៗគ្នា និងតើសញ្ញាណធនធានមានលក្ខណៈដូចម្តេចដែរ?

ករណីសិក្សា៖

## បទពិសោធន៍របស់កន្និកានៅក្នុងមណ្ឌលស្នាក់នៅ និងការថែទាំតាមគ្រួសារ

កន្និកា គឺនៅពេលនាងនៅតូចនៅឡើយត្រូវបានគេរំលោភបំពានផ្លូវភេទ។ ឪពុកម្តាយរបស់នាងបាន ធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ ហើយកន្និកាត្រូវបានបញ្ជូនឱ្យទៅរស់នៅជាមួយជីដូនរបស់នាង។ ប្អូនប្រុសរបស់ឪពុកចុងនាងដែលត្រូវជាពូរបស់នាង ក៏រស់នៅជាមួយជីដូនរបស់នាងដែរ។ នៅពេលដែលកន្និកាមានអាយុ១៣ឆ្នាំ ពូរបស់នាងបានរំលោភផ្លូវភេទនាង។ គាត់បានគម្រាមបង្កគ្រោះថ្នាក់ដល់នាង និងគ្រួសាររបស់នាង ប្រសិនបើនាងនិយាយរឿងនេះប្រាប់គេ ដូច្នេះ កន្និកា ក៏មិនហ៊ាននិយាយ។ នៅពេលដែលឪពុក ម្តាយរបស់នាងត្រឡប់មកវិញពួកគេបានកត់សម្គាល់ថាការអាកប្បកិរិយារបស់កន្និកា បានផ្លាស់ប្តូរយ៉ាងខ្លាំង។ ក្រោយពីបានសាកសួរជាច្រើនដង ទីបំផុត កន្និកាក៏ប្រាប់ឪពុកម្តាយរបស់នាងអំពីអ្វីដែលបានកើតឡើង។

ក្រោយពេលពិភាក្សានៅក្នុងគ្រួសារមក ជីដូនរបស់កន្និកា ក៏បានបណ្តេញពូម្នាក់នោះពីផ្ទះរបស់គាត់ ហើយ អាជ្ញាធរមូលដ្ឋានបានបញ្ជូន កន្និកាទៅអង្គការហាហ្គា ដើម្បីទទួលកិច្ចគាំទ្រ។ របាយការណ៍មួយត្រូវបានធ្វើឡើងទៅនគរបាល ប៉ុន្តែអាស្រ័យដោយជនល្មើសបានគេចខ្លួនបាត់ ដូច្នេះក៏ពុំមានដំណើរការនីតិវិធីតុលាការអ្វីឡើយ។

កន្និកាត្រូវបានបញ្ជូនទៅអង្គការហាហ្គា និង ត្រូវបាននាំយកទៅរស់នៅក្នុងមណ្ឌលមួយរបស់អង្គការហាហ្គា ដែលនាងទទួលបានការផ្តល់ប្រឹក្សា និងការស្តារនីតិសម្បទា។ កន្និកាត្រូវចំណាយពេលមួយចំនួនដើម្បីសម្របខ្លួនទៅនឹងភាពខុសគ្នារវាងជីវិតនៅក្នុងគ្រួសារ និង សហគមន៍ និង ជីវិតនៅក្នុងមណ្ឌល។ នាងបានទទួល បទពិសោធន៍បាត់បង់ភាពឯករាជ្យ និងអារម្មណ៍ជាលក្ខណៈបុគ្គល។ នាងលែងអាចធ្វើដំណើរជុំវិញសហគមន៍បានដោយសេរី និង គ្រាន់តែអាចចាកចេញពីមណ្ឌលជាក្រុមប៉ុណ្ណោះ។ សាលារៀនត្រូវបានផ្តល់ជូននៅនឹងកន្លែង ហើយនាងក៏លែងមានការទទួលខុសត្រូវអ្វីទាំងអស់ អាស្រ័យដោយរាល់អាហារ និងការងារទាំងអស់ត្រូវបានបុគ្គលិកជាអ្នករ៉ាប់រងធ្វើទាំងអស់។ នាងចាប់ផ្តើមមានអារម្មណ៍លែងចង់ធ្វើអ្វីទាំងអស់ និង ពិបាកក្នុងការជម្រុញលើកទឹកចិត្ត។

កន្និកា បានរាប់អានមិត្តភក្តិជាមួយក្មេងស្រីដទៃទៀតនៅក្នុងមណ្ឌល ប៉ុន្តែ ជម្លោះ និង ការប្រកែកគ្នារវាងកុមារទាំងនេះរមែងតែងកើតឡើងជារឿយៗ។ បញ្ហានេះជាទូទៅបណ្តាលពីអាកប្បកិរិយាប្រកបដោយការប្រឈមរបស់កុមារ ដែលមានឫសគល់កើតឡើងពីការបាក់ស្មារតីរបស់ពួកគេ។

បន្ទាប់ពីស្នាក់នៅក្នុងមណ្ឌលមួយរយៈពេលមក អង្គការហាហ្គាបានសម្រេចចិត្តបិទមណ្ឌល និងធ្វើសមាហរណកម្ម កុមារគ្រប់រូបឱ្យទៅទទួលការថែទាំក្នុងគ្រួសារវិញ។ បន្ទាប់ពីធ្វើការប៉ាន់ប្រមាណរួចមក គេយល់ឃើញថាវាគឺជាឧត្តមប្រយោជន៍សម្រាប់កន្និកា ក្នុងការទុកដាក់នាងឱ្យរស់នៅជាមួយគ្រួសារធម៌។ ឪពុកម្តាយធម៌របស់កន្និកា បានធ្វើការងារជាមួយកន្និកា ដើម្បីជួយនាងក្នុងការសម្របជីវិតរស់នៅក្នុងគ្រួសារ និង សហគមន៍ឡើងវិញ  ព្រមទាំងដើម្បីទទួលបានមកវិញនូវភាពឯករាជ្យផងដែរ។ កន្និកាបន្តទទួលបានកិច្ចគាំទ្រផ្តល់ប្រឹក្សាពីអង្គការហាហ្គា និង កិច្ចគាំទ្រប្រចាំថ្ងៃពីឪពុកម្តាយធម៌របស់នាង ដែលបានទទួលការបណ្តុះបណ្តាលពីអង្គការហាហ្គា អំពីរបៀបធ្វើការងារជាមួយកុមារបាក់ស្មារតី និង កុមារដែលមានអាកប្បកិរិយាប្រឈម។ បន្ទាប់ពីរស់នៅក្នុងគ្រួសារធម៌មួយរយៈពេលមក កន្និកា បានបង្ហាញឱ្យឃើញនូវភាពរីកចម្រើនគួរឱ្យកត់សម្គាល់ចំពោះការលើកទឹកចិត្តរបស់នាង ភាពធន់ និងភាពឯករាជ្យរបស់នាង។ នាងបន្តរស់នៅជាមួយគ្រួសារនេះអស់រយៈពេលជាច្រើនឆ្នាំរហូតដល់ពេលដែលនាងបញ្ចប់មធ្យមសិក្សាទុតិយភូមិ និង បន្តទៅសិក្សាកម្រិតសកលវិទ្យាល័យនៅឯទីក្រុង។ អង្គការហាហ្គា បានបន្តផ្តល់កិច្ចគាំទ្រតាមដានរហូតដល់ពេលដែលកន្និកា សម្រេចបានភាពឯករាជ្យពេញលេញទាំងស្រុង។